**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** : ០១៧/២៥ ក.ប/ស.ជ.ណ.ម.ព

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបន្ថែមប្រភេទការងារសម្រាប់ការបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសសិង្ហបុរី

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជន ជាពិសេសអ្នកដែលមានបំណងទៅធ្វើការនៅប្រទេសសិង្ហបុរី និងទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ឱ្យបានជ្រាបថា រដ្ឋាភិបាលនៃប្រទេសសិង្ហបុរី បានសម្រេចបញ្ចូលប្រទេសកម្ពុជាទៅក្នុងបញ្ជីនៃប្រភពទីផ្សារការងារមិនមែនប្រពៃណី (Non-Traditional Sources - NTS) សម្រាប់ការបញ្ជូនពលករទៅធ្វើការនៅប្រទេសសិង្ហបុរី ដែលអនុញ្ញាតឱ្យនិយោជកក្នុងប្រទេសសិង្ហបុរី ទទួលយកពលករខ្មែរទៅធ្វើការក្នុងប្រភេទការងារផ្សេងបន្ថែមទៀត ដូចជាការងារក្នុងវិស័យកម្មន្តសាល សេវាកម្ម សំណង់ និងផលិតនាវា ចាប់ពី**ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៥ នេះតទៅ**។ ក្នុងន័យនេះ ទីភ្នាក់ងារជ្រើសរើសឯកជនដែលទទួលបានការអនុញ្ញាតឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសសិង្ហបុរីទាំងអស់ អាចបញ្ជូនពលករខ្មែរទៅធ្វើការក្នុងប្រភេទការងារខាងលើបន្ថែមលើការងារផ្ទះ និងការផ្តល់សេវាតាមផ្ទះនាពេលបច្ចុប្បន្ន ដោយត្រូវគោរពតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ព្រមទាំងត្រូវអនុវត្តនូវនីតិវិធីនៃការបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសសិង្ហបុរី។

ទីភ្នាក់ងារជ្រើសរើសឯកជនដែលទទួលបានការអនុញ្ញាតឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសសិង្ហបុរី អាចទំនាក់ទំនងផ្ទាល់ជាមួយទីភ្នាក់ងារជ្រើសរើសសិង្ហបុរីដែលទទួលបានការអនុញ្ញាត ដើម្បីធ្វើការជ្រើសរើស និងបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសសិង្ហបុរី (បញ្ជីឈ្មោះទីភ្នាក់ងារសិង្ហបុរីមានផ្សព្វផ្សាយលើគេហទំព័រ https://service2.mom.gov.sg/eadirectory/ ឬអាចទំនាក់ទំនងតាមរយៈអ៊ីមែល mom_fmmd@mom.gov.sg ដើម្បីសាកសួរព័ត៌មានលម្អិតបន្ថែម)។ ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ក៏អាចធ្វើការដោយផ្ទាល់ជាមួយនិយោជកនៅប្រទេសសិង្ហបុរីដែលជាក្រុមហ៊ុនទទួលធំៗ ផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសអ្នកដែលមានបំណងទៅធ្វើការនៅប្រទេសសិង្ហបុរី ជ្រាបជាព័ត៌មាន និងទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ ចូលរួមជំរុញការបញ្ជូនពលករទៅធ្វើការនៅប្រទេសសិង្ហបុរី ក្នុងប្រភេទការងារថ្មីខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៥
**រដ្ឋមន្ត្រី**

**ហេង សួរ**

**ចម្លងជូន៖**
- សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA)
- ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ កាលប្បវត្តិ